

# នីណូ កូននាគវេទមន្ត

Created collaboratively at the mEducational Alliance

Vinayak Varma, Priya Kuriyan

Let's Read
The Asia Foundation



សត្វនាគមកពីគ្រប់ភូមិស្រុកកំពុងមមាញឹកត្រៀមខ្លួនសម្រាប់ការប្រលងប្រជែង "កំពូលនាគព្រួសភ្លើង" ប្រចាំឆ្នាំ។
តែកូននាគនីណូ វិញខុសគេ គេគិតតែសំងំដេកសំដិលថ្ងៃស៊ីស្វាយធ្វើព្រងើយ។
ឃើញនីណូ ដេកលេងចឹងគ្រប់គ្នាកុំច្រឡំថាគេអត់ចង់ទៅប្រលងឲ្យសោះ។
នីណូ
ចង់ទៅណាស់ហើយ ចង់ខ្លាំងទៀតផង....គ្រាន់តែ...គ្រាន់តែថាគេហ្នឹងរៀងខ្ជិលបន្តិច។



ចុងក្រោយនីណូ ក៏សម្រេចចិត្តធ្វើដំណើរទៅប្រកួត។ នៅតាមផ្លូវ នីណូ ហាត់ព្រួសភ្លើង គេចង់ព្រួសឲ្យចេញភ្លើងដែលមានពណ៌លឿងលឿងដូចមាស។



ប៉ុន្តែផ្សែងបែរជាពណ៌ប្រផេះទៅវិញ!

«អូ! នាគមិនព្រួសចេញផ្សែងពណ៌ប្រផេះទេ កូន!»ម្តាយនីណូបាននិយាយទាំងបារម្ភ ។



កូននាគនីណូ ដ៏កំសត់ក៏ទៅពួនយំ។

គេសួរខ្លួនឯងថា ៖ «តើមើលទៅខ្ញុំអាចព្រួសភ្លើង ដើម្បីឲ្យម៉ាក់មានមោទនភាពចំពោះខ្ញុំបានដែរឬទេ?»



ភ្លាមៗនោះ នីណូ បានជួបគ្រូបង្វឹករបស់គេឈ្មោះ បិសាចម្ទេស។
គាត់បានឱ្យ នីណូ ញ៉ាំម្ទេសជាអាហារ។



ម្ទេសទាំងនោះ ពិតជាបញ្ចេញប្រសិទ្ធភាពរបស់វាមែន!
ហើយ នីណូ ក៏ហាត់ហើយហាត់ទៀត។ មិនយូរប៉ុន្មាន...
នីណូ ក៏អាចព្រួសភ្លើងពណ៌មាស បាន។



ជាមួយនឹងសមត្ថភាពថ្មី និងពន្លឺនៃភ្លើងរបស់នីណូ គេអាចបំភ្លឺដែនសមុទ្រឲ្យនាវាជាច្រើនធ្វើដំណើរ។

ចាប់ពីថ្ងៃនោះមក គ្មានកប៉ាល់ ឬនាវាណាមួយវង្វេងផ្លូវសមុទ្រទៀតទេ។

ម្ដាយរបស់នីណា ក៏មានមោទនភាពចំពោះគេដែរ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Drake the Magical Dragon*, Author: Created collaboratively at the mEducational Alliance. Illustrator: Vinayak Varma, Priya Kuriyan. Published by StoryWeaver Community, © StoryWeaver Community. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Somey Chheang